**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តតាកែវ**
សាលក្រមរដ្ឋប្បវេណីលេខ:០៥(ង )
ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តតាកែវ

-បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅសាលសវនាការ នៃសាលាដំបូងខេត្តតាកែវ
-កាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសសាលក្រមនៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០ ។

**ចៅក្រម: លោក** [redacted]
**ក្រឡាបញ្ជី: លោក** [redacted]
**ចេញសាលក្រមដែលមានខ្លឹមសារដូចតទៅ:**

– **រវាងដើមចោទឈ្មោះ** [redacted] **ចាន់ធា** ភេទស្រី អាយុ២១ឆ្នាំ របររកស៊ីកម្មកររោងចក្រ លំនៅបច្ចុប្បន្ន [redacted] ។ ដោយមានលោក [redacted] និងលោក [redacted] ជាមេធាវីតំណាងឲ្យអាណត្តិអោយដើមចោទ ។

– **ចុងចម្លើយឈ្មោះ** [redacted] **ចន្ថា** ភេទប្រុស អាយុ៣៣ឆ្នាំ របររកស៊ីមិនពិតប្រាកដ លំនៅបច្ចុប្បន្នភូមិ [redacted]។

## អង្គហេតុ និង ចំណុចវិវាទ

១-សាលក្រមដែលទាមទារដោយដើមចោទ៖

– ប្តីសុំលែងលះប្តី
– ប្តឹងសុំសិទ្ធិគ្រប់គ្រងកូនចំនួន០១នាក់ ឈ្មោះ [redacted] សុខដាវី ភេទស្រី អាយុ០៣ខែ

២-ការពន្យល់ត្រួសៗអំពីរឿងក្តី៖

– **ដើមចោទឈ្មោះ** [redacted] **ចាន់ធា** និងចុងចម្លើយឈ្មោះ [redacted] **ចន្ថា** បានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមប្រពៃណី កាលពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៨ មកម្លេះ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ ផងដែរ ។ ក្រោយរៀបអាពាហ៍ពិពាហ៍រួច ពួកខ្លួនទាំងពីរនាក់បានរួមរស់នៅជាមួយគ្នាបង្កើតបានកូនចំនួន ០១នាក់ ឈ្មោះ [redacted] **សុខដាវី** ភេទស្រី កើតនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ។

ចំពោះមូលហេតុដែលនាំអោយគូភាគីបែកបាក់គ្នា ដោយសារតែពួកខ្លួនទាំងពីរនាក់រស់នៅមិនចុះសម្រុងរវាងគ្នា និងគ្នាឡើយ ដោយមូលហេតុការរួមរស់ជាមួយគ្នាកន្លងមក ចុងចម្លើយតែងតែជេរប្រមាថ បរិ-ហាកេរ្តិ៍ និងគម្រាមសម្លាប់លើអាយុជីវិតខ្លួនជារឿយៗ ។ ទង្វើបែបនេះធ្វើអោយខ្លួនរស់ជាមួយមិនបានខ្លាច



Scanned with CamScanner

ថ្ងៃណាមួយ ចុងចម្លើយប្រើអំពើហិង្សា ឬ សម្លាប់ខ្លួន មិនតែប៉ុណ្ណោះប្តីរបស់ខ្លួន បានប្រើប្រាស់គ្រឿងញៀនថែមទៀតរហូតសមត្ថកិច្ចបានចាប់ឃាត់ខ្លួន និងបញ្ជូនមកតុលាការទៀតផង ។ នេះជាមូលហេតុធ្វើអោយខ្លួនអស់មនោសញ្ចេតនាពីចុងចម្លើយមិនអាចរួមរស់នៅជាមួយគ្នាតទៅទៀតបានឡើយ ។

៣-អង្គហេតុដែលគ្មានវិវាទៈ

- គ្មាន

៤-អង្គហេតុដែលមានវិវាទៈ

- ចុងចម្លើយមិនឯកភាពក្នុងការលែងលះ
- មិនឯកភាពក្នុងការបែងចែកអំណាចមេបាលើកូន ០១នាក់ ឈ្មោះ [redacted] សុខដាវី ភេទស្រី អាយុ០៣ខែ

៥-សេចក្តីថ្លែងការណ៍របស់គូភាគីៈ

ក- ដើមចោទឈ្មោះ [redacted] ចាន់ធា បានធ្វើសេចក្តីថ្លែងការណ៍ថា ក្នុងរឿងនេះ ខ្លួននៅតែសុំលែងលះ សុំសិទ្ធិអំណាចមេបាលើកូន០១នាក់ឈ្មោះ [redacted] សុខដាវី ភេទស្រី អាយុ០៣ខែ ដោយសំអាងហេតុថាពួកខ្លួនបានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមប្រពៃណីនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៨ មកម្ល៉េះនិងបានចុះសំបុត្រអាពាហ៍ពិពាហ៍រួចហើយ។ ក្នុងការរួមរស់នៅជាមួយគ្នា កន្លងមកពួកខ្លួនរស់នៅមិនចុះសម្រុងនឹងគ្នាចេះតែមានទំនាស់ជាមួយគ្នាជាញឹកញាប់រហូតចុងចម្លើយបានប្រើពាក្យសម្តីជេរប្រមាថ មិនតែប៉ុណ្ណោះ ប្តីរបស់ខ្លួនបានប្រើប្រាស់គ្រឿងញៀនថែមទៀតរហូតសមត្ថកិច្ចបានចាប់ឃាត់ខ្លួន និងបញ្ជូនមកតុលាការទៀតផង កន្លងមកធ្លាប់ធ្វើកិច្ចសន្យាក៏មិនស្តាប់ដែរ ។ចំពោះបញ្ហាកូននាងខ្ញុំ និងប្តីបានបង្កើត បានកូនម្នាក់ឈ្មោះ [redacted] សុខដាវី ភេទស្រី អាយុ០៣ខែ ហើយសព្វថ្ងៃនេះស្ថិតនៅ លើនាងខ្ញុំជាអ្នកគ្រប់គ្រងដោយនាងខ្ញុំពុំសុំទាមទារប្រាក់អាហារកិច្ចចិញ្ចឹមកូនពីប្តីទេដោយសាសព្វថ្ងៃនេះប្តីរបស់នាងខ្ញុំកំពុងជាប់ពន្ធនាគារ។ ម៉្យាងវិញទៀតចំពោះបញ្ហាទ្រព្យសម្បត្តិរួមនាងខ្ញុំនិងប្តីគ្មានអ្វីពាក់ព័ន្ធ និងគ្នាទេ ។

- ខ្លួនសំណូមពរសុំអោយតុលាការចេញសាលក្រមដូចខាងក្រោមៈ
- សុំសាលក្រមលែងលះពីប្តី
- សុំសិទ្ធិគ្រប់គ្រងកូនប្រុស០១នាក់ ឈ្មោះ [redacted] សុខដាវី ភេទស្រី អាយុ ០៣ខែ
- ប្រាក់ប្រដាប់ក្តីខ្លួនជាអ្នកទទួលបន្ទុក ។

ខ- ចុងចម្លើយឈ្មោះ [redacted] ចន្ថា បានធ្វើសេចក្តីថ្លែងការណ៍ថា នៅក្នុងរឿងនេះដើមចោទបានសុំលែងលះពីខ្លួន ខ្លួនមិនឯកភាពទេ ពីព្រោះ ខ្ញុំបាទសព្វថ្ងៃកំពុងជាប់ពន្ធនាគារខេត្តតាកែវ ហើយបើសិនខ្ញុំបាទបានចេញពីពន្ធនាគារខេត្តតាកែវវិញ ខ្ញុំបាទឯកភាពលែងលះ ។ ចំពោះដើមចោទបានលើកឡើងខាងលើថាខ្ញុំបាទបានគម្រាមសម្លាប់លើអាយុជីវិតខ្លួនជារឿយៗនិងជេរប្រមាថទៅលើប្រពន្ធនោះ គឺពុំពិតទេ ។ ចំណែកកូនម្នាក់ដែលដើមចោទសុំសិទ្ធិគ្រប់គ្រងខ្ញុំបាទពុំជំទាស់ដែលគឺខ្ញុំបានឯកភាពប្រគល់កូនម្នាក់ទៅឲ្យដើមចោទ ។ ចំពោះបញ្ហាទ្រព្យសម្បត្តិរួមខ្ញុំបាទនិងប្រពន្ធពិតជាគ្មានអ្វីពាក់ព័ន្ធ និងគ្នាប្រាកដមែន ។



Scanned with CamScanner

៦.ភស្តុតាងជាឯកសារមាន:

- ពាក្យបណ្ដឹង ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ របស់ដើមចោទ
- សំបុត្រអាពាហ៍ពិពាហ៍លេខ: ២០២ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៧ របស់មន្ត្រីអត្រានុកូលដ្ឋានឃុំតាភេម
- សំបុត្រកំណើតកូនលេខ: ៧៨ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ របស់មន្ត្រីអត្រានុកូលដ្ឋានឃុំតាភេម

**សំអាងហេតុ**

- តាមលទ្ធផលនៃការសាកសួរភាគីដើមចោទ និងចុងចម្លើយពិនិត្យភស្តុតាងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា៖

១-ពាក្យបណ្ដឹងចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] **ចាន់ធា** ធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមច្បាប់តុលាការទទួលដោះស្រាយ និង វិនិច្ឆ័យតាមមាត្រា៧ ,មាត្រា៨ ,មាត្រា១០ និងមាត្រា៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២-ដើមចោទនិងចុងចម្លើយបានរៀបពិពាហ៍ពិពាហ៍តាមប្រពៃណីកាលថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៧ មែន និងបាននាំគ្នាទៅចុះសំបុត្រអាពាហ៍ពិពាហ៍ពេញលក្ខណៈស្របតាមមាត្រា៩៥៥ នៃក្រមរដ្ឋប្បវេណី ។ ហេតុនេះចាត់ទុកថា គូភាគីរួមរស់ជាមួយគ្នាស្របតាមបញ្ញត្តិច្បាប់ គប្បីតុលាការសម្រេចតាមច្បាប់ ។

៣-ដើមចោទឈ្មោះ [redacted] **ចាន់ធា** បានប្ដឹងសុំលែងលះពីចុងចម្លើយ សុំសិទ្ធិអំណាចមេបាលើកូន ០១ នាក់ ចុងចម្លើយមិនយល់ព្រមក្នុងលែងលះទេ ។ ចំណុចនេះ តុលាការពិចារណាឃើញថា ការលើកឡើងពីមូលហេតុ និងការទាមទារលែងលះរបស់ដើមចោទមានលក្ខណៈសមរម្យស្របទៅនឹងមាត្រា៩៧៨ ចំណុ-ច (ង) នៃក្រមរដ្ឋប្បវេណី ហើយចំណុចនេះ គប្បីតុលាការពិចារណា ។

៤-ចុងចម្លើយអះអាងថា ការលើកឡើងរបស់ដើមចោទ ខ្លួនទទួលស្គាល់ ខ្លួនពិតជាមានទំនាស់ បន្តិ-ចបន្តួចជាមួយដើមចោទ ទៅលើដើមចោទមែន ។ នៅក្នុងរឿងនេះខ្លួនមិនព្រមលែងលះពីដើមចោទទេខ្លួននៅមានមនោសញ្ចេតនាជាមួយដើមចោទ ។ ចំណុចនេះតុលាការពិចារណាឃើញថា ទោះបី ខិតខំ ផ្សះផ្សារសម្របសម្រួលឲ្យគូភាគីទាំងពីរព្រមរួមរស់ នឹងគ្នាវិញ នៅគ្រប់ដំណាក់នៃនីតិវិធីទាំងអស់តែដើមចោទពុំមាន គំនិតសះជាជាមួយចុងចម្លើយទេ ចំណុចនេះ គប្បីតុលាការ ពិចារណា ។

៥-ចុងចម្លើយអះអាងថាបើសិនដើមចោទសុំលែងលះពីខ្លួនៗ មិនឯកភាពក្នុងការលែងលះជាមួយដើមចោទ ។ ចំណុចនេះតុលាការពិចារណាឃើញថា ពុំមានចែងនៅក្នុងក្រមរដ្ឋប្បវេណីឡើយ ។

៦-ដើមចោទ និង ចុងចម្លើយមានកូនចំនួន០១នាក់ ឈ្មោះ [redacted] សុខដាវី ភេទស្រី អាយុ០៣ខែ កើតនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ។ ស្ថិតនៅលើដើមចោទបីបាច់ថែរក្សា ហើយចុងចម្លើយក៏បានសុំសិទ្ធិអំណាចមេបាដែរ ចំណុចនេះ គប្បីតុលាការពិចារណា ។



Scanned with CamScanner

៧-នៅពេលទាញហេតុផលដោយផ្ទាល់មាត់ ដើមចោទបានទាមទារសិទ្ធិអំណាចមេបាលើកូន ០១នាក់ ចុងចម្លើយ ឯកភាព ហើយមិនទាមទារប្រាក់អាហារកិច្ចចិញ្ចឹមកូនទេ ។ ដូច្នេះគប្បីតុលាការពិនិត្យ និងសម្រេចប្រគល់កូនឈ្មោះ [redacted] **សុខដាវី** ភេទស្រី អាយុ ០៣ខែ កើតនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ឲ្យទៅដើមចោទជាអ្នកមានអំណាចមេបា ។

៨-អ្នកដែលពុំមានសិទ្ធិអំណាចមេបា មានសិទ្ធិចូលជួបនិងប្រាស្រ័យទាក់ទងជាមួយកូនតាមផ្លូវច្បាប់ស្របតាមបទបញ្ញត្តិមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី ។

៩-ដើមចោទ និងចុងចម្លើយអះអាងថា គ្មានទ្រព្យសម្បត្តិរួមទេ ។ គប្បីតុលាការមិនយកមកពិចារណាទេ ។

១០-ដើមចោទទទួលបន្ទុកលើប្រាក់ប្រដាប់ក្តី ។

## <u>សេចក្តីសម្រេចបញ្ចប់</u>

១-ឲ្យដើមចោទឈ្មោះ [redacted] ចាន់ជា និងចុងចម្លើយឈ្មោះ [redacted] ចន្ថា លែងលះគ្នាចាប់ពីពេលនេះតទៅ ។

២-ដើមចោទឈ្មោះ [redacted] ចាន់ជា ជាអ្នកមានសិទ្ធិមេបាលើកូនចំនួន ០១នាក់ ឈ្មោះ [redacted] **សុខដាវី** ភេទស្រី កើតនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ។

៣-ដើមចោទត្រូវបង្កលក្ខណៈងាយស្រួលដល់ចុងចម្លើយ ក្នុងការសួរសុខទុក្ខ និងការប្រាស្រ័យទាក់ទង ចំពោះកូនតាមច្បាប់ស្របតាមមាត្រា១០៤០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីដើមចោទ ។

ថ្ងៃច័ន្ទ ៥រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
តាកែវ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០

**ចៅក្រម**

**ហត្ថលេខា និងត្រា៖** [redacted]

---

**អនុសារសាលក្រមនេះ បានចម្លងត្រឹមត្រូវតាមលិខិតសាលក្រមដើម ដើម្បីឲ្យទៅភាគី**

ថ្ងៃច័ន្ទ ៥រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
តាកែវ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

បានឃើញ
ថ្ងៃច័ន្ទ ៥រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
តាកែវ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០

**ចៅក្រមទទួលបន្ទុក**

[redacted]



Scanned with CamScanner